# ជនគណនា Numbers

កណ្ឌនេះមានចំណងជើងថា «ជនគណនា» ពីព្រោះវាមានការរាប់ចំនួនមនុស្សនៅជំពូក១ និង២៦។

ជាច្រើនឆ្នាំនៅក្នុងទីរហោស្ថានគឺជាពេលវេលាលំបាក។ ជនជាតិអ៊ីស្រាអែលឃ្លាននិងស្រេកជាញឹកញាប់។ ជាច្រើនដង ពួកគេប្រាថ្នាចង់ត្រឡប់ទៅឯអេស៊ីព្ទវិញ។ មានការរអ៊ូរទាំអំពីការដឹកនាំរបស់ម៉ូសេជាញឹកញាប់។ គ្រប់ការទាំងនេះ ព្រះស្មោះត្រង់ចំពោះសេចក្ដីសន្យារបស់ទ្រង់ ហើយការពារនិងរក្សារាស្ត្ររបស់ទ្រង់។ ជាច្រើនដង ទ្រង់បង្រៀនរាស្ត្ររបស់ទ្រង់យ៉ាងតឹងរឹង ពីព្រោះព្រះស្រលាញ់ពួកគេ និងពីព្រោះព្រះកំពុងបង្រៀនរាស្ត្ររបស់ទ្រង់ថា ពួកគេត្រូវតែបំពេញតួនាទី ដែលទ្រង់បានប្រទានអោយពួកគេ។

## សារៈសំខាន់នៃកណ្ឌជនគណនា Importance of Numbers

កណ្ឌជនគណនាមានសារៈសំខាន់ ពីព្រោះ៖

១. កណ្ឌនេះបើកសំដែងអំពីភាពបរិសុទ្ធរបស់ព្រះ និងព្រះជាម្ចាស់បង្គាប់អ៊ីស្រាអែលអោយមានជីវិតបរិសុទ្ធ។
២. បង្ហាញថា ព្រះជាម្ចាស់ទ្រង់ស្មោះត្រង់ចំពោះសេចក្ដីសន្យារបស់ព្រះអង្គ ទោះបីជារាស្ត្ររបស់ព្រះបានបះបោរប្រឆាំងនឹងទ្រង់ក៏ដោយ។
៣. បង្ហាញអំពីសារៈសំខាន់នៃជំនឿ គឺយើងត្រូវជឿលើសេចក្ដីសន្យារបស់ទ្រង់។
៤. បង្រៀនអំពីផលវិបាកនៃការបះបោរ ហើយជាការព្រមានសម្រាប់យើង កុំអោយបះបោរប្រឆាំងនឹងព្រះអង្គ។

## ប្រវត្តិសាស្ត្រដែលត្រូវបានកត់ត្រាទុកក្នុងកណ្ឌជនគណនា History recorded in Numbers

កណ្ឌជនគណនាបរិយាយអំពីឆ្នាំទាំងប៉ុន្មានដែលជនជាតិអ៊ីស្រាអែលចំណាយនៅក្នុងទីរហោស្ថានស៊ីណាយ។ ក្នុងរវាងការចាកចេញពីភ្នំស៊ីណាយជាមួយរោងឧបោសថ និងការចាប់ផ្ដើមដណ្ដើមយកទឹកដីកាណាន ជនជាតិអ៊ីស្រាអែលមួយជំនាន់រស់នៅនិងស្លាប់នៅក្នុងទីរហោស្ថាន។ កណ្ឌជនគណនារាប់ចំនួនរបស់ពួកគេ ប្រាប់យើងអំពីរបៀបរៀបចំពួកគេ កត់ត្រាអំពីក្រិត្យវិន័យ និងនិទានអំពីការផ្សងព្រេងរបស់ពួកគេ។

ប៉ុន្មានឆ្នាំរស់នៅក្នុងទីរហោស្ថានមានការលំបាកសំរាប់ពួកគេ។ បណ្ដាជនបានរអ៊ូរទាំប្រឆាំងនឹងព្រះ និងបានបះបោរប្រឆាំងនឹងម៉ូសេ។ ជនជាតិអ៊ីស្រាអែលពេញមួយជំនាន់បានធ្វើអោយបាត់បង់សិទ្ធិក្នុងការចូលទៅក្នុងទឹកដីសន្យា។ មានតែយ៉ូស្វេនិងកាលែប ដែលជាមនុស្សដែលបានជឿលើសេចក្ដីសន្យារបស់ព្រះ គឺជាអ្នកមកពីជំនាន់មុន ដែលព្រះបានអនុញ្ញាតអោយចូលទៅក្នុងទឹកដីសន្យា។ ប៉ុន្តែនៅចុងបញ្ចប់កណ្ឌមានមនុស្សជំនាន់ថ្មីមួយជាស្រេចសំរាប់ជ័យជំនះលើការដណ្ដើមទឹកដីសន្យា។

## គម្រោង Outline

កុលសម្ព័ន្ធផ្សេងៗនៅឯភ្នំស៊ីណាយ (១:១-៩:២៣)

ការធ្វើដំណើរពីស៊ីណាយទៅកាន់ម៉ូអាប់ (១០:១-២១:២៥)

ព្រឹត្តិការណ៍ផ្សេងៗនៅម៉ូអាប់ (២២:១-៣២:៤២)

ដំណាក់កាលនៃការធ្វើដំណើររបស់អ៊ីស្រាអែល (៣៣:១-៥៦)

ការត្រៀមខ្លួនសំរាប់ការតាំងទីលំនៅថ្មី (៣៤:១-៣៦:១៣)

## របៀបអានកណ្ឌជនគណនា How to read Numbers

ដើម្បីយល់និងអនុវត្តកណ្ឌជនគណនាបានត្រឹមត្រូវ ជាការសំខាន់យើងត្រូវយល់អំពីកណ្ឌនេះនៅក្នុងបរិបទប្រវត្តិសាស្រ្តដើមរបស់វា និងនៅក្នុងបរិបទនៃព្រះគម្ពីរទាំងមូល។ ដើម្បីយល់បាន យើងត្រូវឆ្លើយនឹងសំនួរចំនួនប្រាំមួយដូចខាងក្រោម។

១. តើកណ្ឌជនគណនាទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌនេះយ៉ាងដូចម្តេចខ្លះ?
២. តើគោលបំណងរបស់កណ្ឌជនគណនាសំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?
៣. តើកណ្ឌជនគណនាទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌនេះយ៉ាងដូចម្តេច?
៤. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីព្រះ?
៥. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីមនុស្ស?
៦. តើកណ្ឌនេះទាក់ទងនឹងគ្រីស្ទបរិស័ទសព្វថ្ងៃនេះយ៉ាងដូចម្តេច?

## ១. តើកណ្ឌជនគណនាទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌនេះយ៉ាងដូចម្តេចខ្លះ?

ព្រះគម្ពីរគឺជារឿងធំមួយ ដែលពន្យល់អំពីផែនការរបស់ព្រះចាប់តាំងពីការបង្កបង្កើតដល់ការបង្កបង្កើតថ្មី។ ទ្រង់បានបង្កើតគ្រប់យ៉ាងល្អជាដំបូង ដោយមានអ័ដាមនិងអេវ៉ានៅក្នុងសួនច្បារអេដែន។ ពួកគេគឺជារាស្រ្តរបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។ នេះគឺជាគោលដៅរបស់ព្រះសំរាប់ការបង្កបង្កើត។ ពួកគេមិនបានស្តាប់បង្គាប់ ហើយត្រូវបានបណ្តេញចេញពីសួនច្បារ ដែលជាទីបរិសុទ្ធរបស់ព្រះ។ កន្លែងផ្សេងៗទាំងអស់ទៀតក្នុងព្រះគម្ពីរនិយាយអំពីផែនការរបស់ព្រះក្នុងការសង្គ្រោះមនុស្សចេញពីលទ្ធផលនៃការបះបោរនេះ ហើយស្តានគររបស់ទ្រង់ឡើងវិញ ដែលជារាស្រ្តរបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។ ដូច្នេះ ព្រះបានជ្រើសរើសអ័ប្រាហាំ ហើយបានសន្យាថា ទ្រង់នឹងធ្វើអោយគាត់ក្លាយជាជាតិសាសន៍មួយដ៏ធំ ហើយពួកគេនឹងទទួលបានទឹកដីសន្យា។ តាមរយៈពូជពង្សរបស់អ័ប្រាហាំ ព្រះនឹងប្រទានពរដល់លោកិយ (លោកុប្បត្តិ ១២:៣)។ ពួកគេត្រូវតែជារាស្រ្តរបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោម

ការគ្រប់គ្រងនិងព្រះពររបស់ព្រះ ។ ទ្រង់នឹងគង់ក្នុងចំណោមពួកគេ ដូច្នេះអ៊ីស្រាអែលនៅក្នុងទឹកដីសន្យាគឺអេដែនថ្មី ដែលជាទីបរិសុទ្ធថ្មី (សូមមើល លោកុប្បត្តិ ១៣:១០)។

ប្រជាជនអ៊ីស្រាអែលត្រូវបានសង្គ្រោះចេញពីទាសភាពនៅក្នុងអេស៊ីព្ទ។ មុនពេលពួកគេចូលទៅក្នុងទឹកដីសន្យា ពួកគេបញ្ជូនអ្នកស៊ើបការណ៍ ហើយជាលទ្ធផលពួកគេមិនជឿថា ពួកគេអាចចាប់យកទឹកដីនោះបាន ហើយការនេះជាការបះបោរប្រឆាំងនឹងព្រះ (ជនគណនា ១៣-១៤)។ ការបះបោរប្រឆាំងនេះបង្កើតសំនួរធំមួយឡើង។ តើការបះបោរប្រឆាំងរបស់ពួកគេមានន័យថា សេចក្តីសន្យារបស់ព្រះនឹងមិនបានសំរេចឬ? តើផែនការណ៍របស់ព្រះក្នុងការដកយកលទ្ធផលចេញពីអំពើបាបរបស់អ័ដាមនិងអេវ៉ាបានបរាជ័យឬ? ចំលើយគឺ ទេ។ មនុស្សជំនាន់ដែលបះបោរ មិនអាចចូលទៅក្នុងទឹកដីសន្យាបានទេ ប៉ុន្តែព្រះនឹងបន្តផែនការណ៍របស់ទ្រង់ក្នុងការដកយកលទ្ធផលចេញពីការបះបោររបស់អ័ដាមនិងអេវ៉ា។ ទ្រង់នឹងមានរាស្ត្ររបស់ទ្រង់ នៅក្នុងទឹកដីរបស់ទ្រង់ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ទ្រង់ ដូច្នេះទ្រង់បានលើកមនុស្សជំនាន់ថ្មីមួយឡើង ដើម្បីចូលទៅក្នុងទឹកដីសន្យា។

## ២. តើគោលបំណងរបស់កណ្ឌជនគណនាសំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?

កណ្ឌជនគណនាបានបង្រៀនជនជាតិអ៊ីស្រាអែលអំពីភាពមិនស្មោះត្រង់របស់ពួកគេចំពោះព្រះ ហើយនិងសេចក្តីមេត្តាករុណាដ៏ធំ ការផ្គត់ផ្គង់ និងភាពស្មោះត្រង់របស់ព្រះចំពោះពួកគេ។

## ៣. តើកណ្ឌជនគណនាទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌនេះយ៉ាងដូចម្តេច?

កណ្ឌជនគណនាទាក់ទងនឹងកណ្ឌផ្សេងៗទៀត ដែលមានបន្ទាប់ ក្នុងរបៀបជាច្រើន។ មានការនិយាយឡើងវិញអំពីការបះបោរនៅក្នុងទីរហោស្ថាន (១៣:១-២០:១៣) នៅក្នុងព្រះគម្ពីរជាច្រើនដង។ ដូចជានៅក្នុងចោទិយកថា ១:២៦-៤០ ម៉ូសេប្រាប់ជនជាតិអ៊ីស្រាអែលជំនាន់ក្រោយថា ការមិនមានជំនឿ និងការបះបោរប្រឆាំងរបស់អ៊ីស្រាអែលចំពោះព្រះបាននាំទៅដល់ការធ្វើដំណើរអស់រយៈពេលយូរនៅក្នុងទីរហោស្ថាន។ អេសេគាល ២០:១៣-១៦ បញ្ចូលការបះបោរប្រឆាំងនៅក្នុងទីរហោស្ថានជាពេលវេលាមួយ ដែលអ៊ីស្រាអែលបាននាំអោយទ្រង់ខឹងនឹងពួកគេ។ ហោរាអេសេគាលប្រកាសថា ព្រឹត្តិការណ៍នៅក្នុងជនគណនា ១៣-១៤ បង្ហាញថា អ៊ីស្រា អែលបានស្រលាញ់រូបព្រះជាជាងព្រះ។ ទំនុកដំកើង ៧៨:១៧-១៩ និង៤០-៥៥ បង្ហាញថាសកម្មភាពរបស់អ៊ីស្រាអែលគឺជាសេចក្តីចំកួត ជាពិសេសពីព្រោះព្រះអង្គបានសង្គ្រោះពួកគេ។ ការនិយាយអំពីព្រឹត្តិការណ៍ទាំងនេះឡើងវិញមានគោលបំណងចង់ព្រមាននិងលើកទឹកចិត្តដល់រាស្ត្ររបស់ព្រះកុំអោយដើរតាមគំរូរបស់អ៊ីស្រាអែលនៅក្នុងទីរហោស្ថាន (សូមមើលទំនុកដំកើង ៩៥:៧-១១)។ ហេព្រើរ ៣:១៥-៤:៧ ដកស្រង់ទំនុកដំកើង ៩៥ ដើម្បីអនុវត្តមកកាន់គ្រីស្ទបរិស័ទ ដែលបង្ហាញថា ការបះបោរប្រឆាំងរបស់អ៊ីស្រាអែល ដោយ

សារការខ្វះសេចក្តីជំនឿរបស់ពួកគេ គឺជាការព្រមានមួយសំរាប់យើងផងដែរ (សូមមើល ១កូរិនថូស ១០:៥-៦ ផងដែរ)។

ការនិយាយឡើងវិញអំពីព្រឹត្តិការណ៍ទាំងនេះគឺដើម្បីបង្រៀនអំពីសេចក្តីមេត្តាករុណានិងសេចក្តីសប្បុរសរបស់ព្រះ ដែលបានប្រទានឱកាសជាលើកទីពីរ ដើម្បីចូលទឹកដីសន្យានិងផ្គត់ផ្គង់សំរាប់រាស្ត្ររបស់ទ្រង់ផងដែរ (អេសេគាល ២០:១៧; អេម៉ុស ២:១០; ទំនុកដំកើង ៧៨:៣៨; ១១៤:១-៨; ១៣៦:១៦)។

ម៉ូសេបានប្រើជ័យជំនះ ដែលព្រះបានប្រទានអោយ លើស្តេចអុក (ជនគណនា ២១:៣២-៣៥) ធ្វើជាភស្តុតាង ដែលព្រះនឹងប្រទានទឹកដីសន្យាដល់អ៊ីស្រាអែល (ចោទិយកថា ៣:១-១១, ២៩:៧-៨, ៣១:១-៤)។ ការយកឈ្នះស្តេចអុកគឺជាមូលហេតុមួយ ដែលរ៉ាហាបនិងសាសន៍គីបៀនបានជឿលើព្រះរបស់អ៊ីស្រាអែល ហើយអ៊ីស្រាអែលនឹងទទួលបានទឹកដីជាមរតក។ ទំនុកដំកើង ១៣៥:១១ និយាយអំពីព្រឹត្តិការណ៍នេះឡើងវិញ ដើម្បីបង្រៀនអំពីអំណាចព្រះចេស្តារបស់ព្រះ ទំនុកដំកើង ១៣៦:២០ ប្រើព្រឹត្តិការណ៍នេះ ដើម្បីបង្រៀនអំពីសេចក្តីស្រលាញ់និងសេចក្តីសប្បុរសរបស់ព្រះ ហើយនេហេមា ៩:២២ ប្រើព្រឹត្តិការណ៍នេះ ដើម្បីបង្រៀនអំពីការជ្រើសរើសរបស់ព្រះ។

មានការប្រើរឿងអំពីបាឡាមជាច្រើនដងនៅក្នុងព្រះគម្ពីរ ដើម្បីព្រមានរាស្ត្ររបស់ព្រះ។ ចោទិយកថា ២៣:៤-៥ បង្រៀនថា គេបានជួលបាឡាមដើម្បីដាក់បណ្តាសា។ ២ពេត្រុស ២:១៥ យូដាស ១១ និងវិវរណៈ ២:១៤ ថ្លែងថា បាឡាមគឺជាសត្រូវរបស់អ៊ីស្រាអែល និងជាហោរាក្លែងក្លាយ។ ពេត្រុសនិងយូដាសប្រៀបធៀបបាឡាមជាមួយពួកគ្រូខុសឆ្គងដែលលោភលន់នៅសម័យរបស់ពួកគាត់ ហើយកណ្ឌវិវរណៈបន្ទោសពួកជំនុំនៅពើកាម៉ុស ដោយពួកគេដើរតាមសេចក្តីបង្រៀនរបស់បាឡាម ដែលរួមបញ្ចូលទាំងការថ្វាយបង្គំរូបព្រះ និងការប្រាសចាកសីលធម៌ផ្លូវភេទ។

ការថ្វាយបង្គំរូបព្រះរបស់អ៊ីស្រាអែលនៅបាល-ពេអរ ត្រូវបានប្រើជាការព្រមានមួយកុំអោយធ្លាក់ចូលក្នុងការថ្វាយបង្គំរូបព្រះ (ចោទិយកថា ៤:៣-៤)។ ហូសេប្រៀបធៀបការថ្វាយបង្គំរូបព្រះរបស់អ៊ីស្រាអែលនៅសម័យរបស់គាត់ទៅនឹងការថ្វាយបង្គំរូបព្រះនៅបាល-ពេអរ (ហូសេ ៩:១០)។ ទំនុកដំកើង ១០៦:២៨ បង្រៀនថា ការថ្វាយបង្គំរូបព្រះរបស់អ៊ីស្រាអែលនៅក្នុងជនគណនា ២៥ គឺជាមូលហេតុមួយដែលធ្វើអោយព្រះបញ្ជូនពួកគេទៅក្នុងការនិរទេស។

## ៤. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីព្រះ?

តាមការរៀបរាប់ខាងលើ យើងឃើញថា កណ្ឌជនគណនាបង្រៀនថា ព្រះ៖

- បានដឹកនាំនិងផ្គត់ផ្គង់សំរាប់រាស្ត្ររបស់ទ្រង់ អ៊ីស្រាអែល នៅក្នុងទីរហោស្ថានយ៉ាងអស្ចារ្យ។
- បង្គាប់រាស្ត្ររបស់ព្រះអោយស្មោះត្រង់ចំពោះសម្ព័ន្ធមេត្រី ដែលព្រះអង្គបានចងជាមួយពួកគេ។

- គឺជាព្រះដ៏បរិសុទ្ធ។
- ត្រាស់ហៅ និងកែប្រែរាស្ត្ររបស់ទ្រង់ (១០:១១-១២:១៦)។
- មានសិទ្ធិនិងអំណាចដាក់ទណ្ឌកម្មលើរាស្ត្ររបស់ទ្រង់ ប្រសិនបើទ្រង់មានបំណងចង់។
- ធ្វើសេចក្តីសន្យារបស់ទ្រង់ជាថ្មី ហើយស្មោះត្រង់ចំពោះសេចក្តីសន្យារបស់ទ្រង់។ ទ្រង់នឹងនាំអ៊ីស្រាអែលទៅដល់ទឹកដីសន្យា ដែលទ្រង់បានសន្យាជាមួយអ័ប្រាហាំតាំងពីរាប់រយឆ្នាំមុន បើទោះជាមនុស្សមួយជំនាន់មិនបានចូល ដោយព្រោះពួកគេបានខ្វះសេចក្តីជំនឿក៏ដោយ។

### ៥. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីមនុស្ស?

- ជាញឹកញាប់ មនុស្សខ្វះសេចក្តីជំនឿលើព្រះបន្ទូលសន្យារបស់ព្រះ។
- មនុស្សដើរតាមអ្វី ដែលពួកគេ *មើលឃើញ* ជាជាងអ្វី ដែលពួកគេ *ស្តាប់ឮ*។ ពួកគេមើលឃើញថា មនុស្សនៅទឹកដីសន្យាខ្លាំងពូកែ ហើយប្រព្រឹត្តតាមអ្វី ដែលពួកគេបាន *មើលឃើញ* ជាជាងអ្វី ដែលពួកគេបាន *ស្តាប់ឮ* ដែលជាព្រះបន្ទូលសន្យារបស់ព្រះ។

### ៦. តើកណ្ឌនេះទាក់ទងនឹងគ្រីស្ទបរិស័ទសព្វថ្ងៃនេះយ៉ាងដូចម្តេច?

តាមការរៀបរាប់ខាងលើ យើងឃើញថា កណ្ឌជនគណនាមានការអនុវត្តជាច្រើន។ យើងត្រូវតែប្រយ័ត្នកុំដើរតាមពួកគ្រូខុសឆ្គង ព្រះគម្ពីរសញ្ញាថ្មីបានប្រៀបធៀបនឹងបាឡាម។ សេចក្តីស្មោះត្រង់របស់ព្រះចំពោះយើងនៅក្នុងព្រះគ្រីស្ទគឺជាការលើកទឹកចិត្តដ៏ធំសំរាប់យើង ដោយយើងដឹងថា គ្មានអ្វីនឹងអាចបញ្ឈប់ព្រះមិនអោយបំពេញសំរេចសេចក្តីសន្យារបស់ទ្រង់ជាមួយអ៊ីស្រាអែលបានឡើយ ហើយសម្រាប់យើងផងដែរ ក៏គ្មានអ្វីនឹងអាចបំបែកយើងចេញពីសេចក្តីស្រលាញ់របស់ព្រះនៅក្នុងព្រះគ្រីស្ទបានដែរ (រ៉ូម ៨:២៨-៣៩)។ ការអនុវត្ត ដែលចេញពីកណ្ឌនេះច្រើនបំផុតនៅក្នុងព្រះគម្ពីរ គឺជាការព្រមានមួយចេញពីគំរូរបស់អ៊ីស្រាអែល ដែលមិនជឿលើសេចក្តីសន្យារបស់ព្រះ និងការបះបោរបន្ទាប់មកទៀត។ ពួកគេបានដើរតាមអ្វី ដែលពួកគេបានមើលឃើញ ជាជាងអ្វីដែលពួកគេបានស្តាប់ឮ។ យើងមានព្រះបន្ទូលសន្យារបស់ព្រះនៅក្នុងដំណឹងល្អរបស់ព្រះគ្រីស្ទ។ យើងត្រូវតែទុកចិត្តលើព្រះបន្ទូលសន្យា ដែលយើងស្តាប់ឮនោះ ហើយការទុកចិត្តនេះនឹងបណ្តាលអោយយើងដើរតាមព្រះបន្ទូលរបស់ព្រះ ជាជាងលោកិយ ដែលយើងមើលឃើញ។